**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**CAMBODIA WATCHDOG COUNCIL INTERNATIONAL**

ក្រុងគ្រីស្ទានសាន់ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦

# សេចក្តីថ្លែងការណ៍

## បញ្ជាក់ជំហរប្រឆាំងជំទាស់ការផ្ទេរខ្នាតផែនទី និង ការកែប្រែរដ្ឋធម្មនុញ្ញ មាត្រា២

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមបញ្ជាក់ជំហរប្រឆាំងជំទាស់ជាដាច់ខាត ចំពោះរដ្ឋាភិបាល ហ៊ុន សែន ដែលបានព្រមព្រៀងគ្នា ជាមួយរដ្ឋាភិបាលវៀតណាម *ផ្ទេរខ្នាតផែនទីព្រំដែន បោន(Bonne) ១/១០០.០០០ មកខ្នាតផែនទី UTM ១/៥០.០០០ វិញ ទៅតាមការចង់បានរបស់ វៀតណាម ដើម្បីឲ្យស្របតាមលទ្ធផល នៃការបោះបង្គោលព្រំដែនបានជាង ៨៣% រួចហើយ តាំងពីឆ្នាំ២០០៦ មកដល់សព្វថ្ងៃ* ។ គោលបំណងនៃ ការផ្ទេរខ្នាតផែនទីនេះ ក៏ជាយន្តការមួយទៀត ដែលនឹងបោះជំហានទៅធ្វើការកែប្រែ រដ្ឋធម្មនុញ្ញ មាត្រា២ ដែលជាឯកសារដ៏រឹងមាំ ការពារបូរណភាពទឹកដីខ្មែរ ទប់ស្កាត់ការរំលោភឈ្លាន ពីប្រទេសវៀតណាម។

យើងសូមជំទាស់យ៉ាងដាច់អហង្កា ចំពោះយន្តការរបស់រដ្ឋាភិបាល ហ៊ុន សែន ដែលឈានទៅរកការកែសម្រួល រដ្ឋធម្មនុញ្ញ មាត្រា២ ពីព្រោះថា *កម្ពុជា នឹងបំបាត់សិទ្ធិតវ៉ាដោយខ្លួនឯង នៅលើវេទិកាអន្តរជាតិ និង បោះបង់ចោលមរតកប្រវត្តិសាស្ត្រ ពីអាណានិគមបារាំង ក្នុងការប្តឹងតវ៉ាទាមទារមកវិញ «ប្រជុំកោះត្រល់ និងទឹកដីព្រំដែនខ្មែរ ដែលបាត់បង់»* ក្នុងរបបដឹកនាំរបស់លោក ហ៊ុន សែន តាំងពីទសវត្សទី៨០ ដល់បច្ចុប្បន្ន។ នេះគឺជាចំណុចគ្រោះថ្នាក់ធ្ងន់ធ្ងរបំផុត ដែលពលរដ្ឋខ្មែរ និងអ្នកនយោបាយខ្មែរ ត្រូវស្វែងយល់ ហើយនិងសិក្សា ឲ្យបានស៊ីជម្រៅទៅលើប្រវត្តិសាស្ត្ររបស់ខ្លួន។

សេចក្តីថ្លែងការណ៍នេះ ជាឯកសារសំខាន់ដែលនឹងបកប្រែជាភាសាអង់គ្លេស ផ្ញើទៅទៅកាន់សហប្រធានហត្ថលេខីនៃ កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១, អគ្គលេខាធិការដ្ឋានអាស៊ាន និងស្ថាប័នពាក់ព័ន្ធឯទៀត ដោយភ្ជាប់ជាមួយនូវលិខិតបញ្ជូន របស់ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា។

### ១. ហេតុអ្វីបានជាយើង មិនគាំទ្រការផ្ទេរខ្នាតផែនទីព្រំដែន?

គោលបំណងនៃការផ្ទេរខ្នាតផែនទីព្រំដែន មិនមែនជារឿងថ្មីទេ ដែលភាគីវៀតណាម បង្ខំឲ្យរដ្ឋាភិបាល ហ៊ុន សែន ត្រូវតែអនុវត្តឲ្យបានជាវិជ្ជមាន។ ការអនុវត្តសន្ធិសញ្ញា ក្នុងការបោះបង្គោលព្រំដែន រដ្ឋាភិបាលកម្ពុជា



អសយដ្ឋានទំនាក់ទំនង ទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស៍ /ប្រអប់សំបុត្រ៖ # Senterveien 40, Apartment 112, 4790 Lillesand, NORWAY /Phone: (+47) 90 81 82 57 /E-mail: nathamonin@gmail.com

ខ្លួនឯង បានរំលោភរដ្ឋធម្មនុញ្ញ មាត្រា២ ដែលការពារបូរណភាពទឹកដីខ្មែរ ដោយបើកឲ្យប្រើ ផែនទីខ្នាតបោន (Bonne) ១/១០០.០០០ ប៉ុន្តែរដ្ឋាភិបាល បែរជាប្រើប្រាស់ផែនទី UTM ខ្នាត ១/៥០.០០០ តាមការទាមទាររបស់ភាគីវៀតណាម។ ម្ល៉ោះហើយរដ្ឋាភិបាល ហ៊ុន សែន ត្រូវតែលាក់លៀមឯកសារព្រំដែនទាំងអស់ មិនបញ្ចេញឲ្យពលរដ្ឋខ្មែរ, អ្នកនយោបាយខ្លះ, និងសមាជិករដ្ឋសភា បានយល់ដឹងនោះទេ។

ការព្រមព្រៀងគ្នា រវាងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាមួយលោកនាយករដ្ឋមន្ត្រី ង្វៀង ស៊ុនហ៊្វុក (Nguyen Xuan Phuc) នៃប្រទេសវៀតណាម កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ គឺជាការរំលឹកឡើងវិញ អំពីខ្លឹមសារសំខាន់ៗ មានចែងក្នុងសន្ធិសញ្ញាព្រំដែនខុសច្បាប់ ឆ្នាំ១៩៨៥ នាសម័យវៀតណាម ត្រួតត្រាកម្ពុជា និងសន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ២០០៥។ ***ដូច្នេះ ការផ្ទេរខ្នាតផែនទីព្រំដែន ពីខ្នាតបោន(Bonne) ១/១០០.០០០ មកខ្នាតផែនទី UTM ១/៥០.០០០ គឺគ្រាន់តែជាការបង្គ្រប់កិច្ច និងជាធ្វើឲ្យស្របតាម ការបោះបង្គោលព្រំដែន បានជាង ៨៣% រួចហើយនោះ***។

សន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ២០០៥ ដែលទទួលស្គាល់ឡើងវិញនូវ សន្ធិសញ្ញាព្រំដែនខុសច្បាប់ ឆ្នាំ១៩៨៥ មានចែងស្នើរគ្រប់ចំណុច ត្រង់ប្រការ ២ និងប្រការ ៣ ដោយគូសបញ្ជាក់ថា «***ភាគីទាំងពីរ បានឯកភាពគ្នា ដើម្បីកែសម្រួលខ្សែបន្ទាត់ព្រំដែន ក្នុងការពិនិត្យផ្ទៀងផ្ទាត់ ការចម្លងខ្សែបន្ទាត់ព្រំដែន ពីផែនទី Bonne ខ្នាត ១/១០០.០០០ មកលើផែនទី UTM ខ្នាត ១/៥០.០០០***»។ ហើយនៅប្រការ ៤ នៃសន្ធិសញ្ញានេះ បានបញ្ជាក់ដែរថា ភាគីទាំងពីរ ប្រើផែនទី Bonne *១/១០០.០០០* ចំនួន ២៦ ផ្ទាំង និងផែនទី UTM ខ្នាត ១/៥០.០០០ ចំនួន ៤០ ផ្ទាំង (ជាផែនទីដែលផលិតដោយកងទ័ពអាមេរិក ក្នុងសម័យសង្គ្រាមវៀតណាម) ដែលជាផែនទីអម សន្ធិសញ្ញាព្រំដែនខុសច្បាប់ ឆ្នាំ១៩៨៥ ។

លោក វ៉ា គឹមហុង ទេសរដ្ឋមន្ត្រី ជាប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា របស់រដ្ឋាភិបាល បានសារភាពក្នុងសន្និសីទ ពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ថា ផែនទីទាំង ២ ប្រភេទនេះ «**ជាផែនទី ផលិតនៅប្រទេសវៀតណាម**»។ វាជាការពិត នៅលើផែនទី ក៏មានបញ្ជាក់ដោយ«ហត្ថលេខា» ពីសមភាគី កម្ពុជា (**លោក ឌិត មន្ទី** ប្រធានគណៈប្រតិភូ នៃរដ្ឋាភិបាលកម្ពុជា) និង វៀតណាម (**លោក លីវ វ៉ាន់ ឡើយ** ប្រធានគណៈប្រតិភូ នៃរដ្ឋាភិបាលវៀតណាម) កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥។

ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ លោក វ៉ា គឹមហុង បានថ្លែងសារភាព នៅក្រសួងមហាផ្ទៃថា «**ភាគីកម្ពុជាយើង ចង់បោះបង្គោលព្រំដែន តាមផែនទីបោន**(Bonne) **ខ្នាត ១/១០០.០០០ ប៉ុន្តែវៀតណាម មិនព្រម។ ភាគីវៀតណាម ទាមទារឲ្យកម្ពុជា ត្រូវបោះបង្គោលព្រំដែន តាមផែនទីខ្នាត** UTM **ខ្នាត ១/៥០.០០០**»។

## ២. ប្រវត្តិនៃការបោះបង្គោលព្រំដែន និង ការរំកិលខ្សែបន្ទាត់ព្រំដែនថ្មី

រដ្ឋាភិបាល ហ៊ុន សែន បានបោះបង់ចោលខ្សែបន្ទាត់ព្រំដែន ដែលជាកេរមរតក ពីរបបអាណានិគមបារាំង ***តាមអនុសញ្ញាបារាំង កម្ពុជា និងកូសាំងស៊ីន(កម្ពុជាក្រោម) នាឆ្នាំ១៨៧៣ ដែលកាលនោះ បារាំង បានបោះ***



អសយដ្ឋានទំនាក់ទំនង ទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស៍ /ប្រអប់សំបុត្រ៖ # Senterveien 40, Apartment 112, 4790 Lillesand, NORWAY /Phone: (+47) 90 81 82 57 /E-mail: nathamonin@gmail.com

***បង្គោលព្រំដែនចំនួន ១២៤ បង្គោល។*** មរតករបស់បារាំងនេះ បានសរសេរនៅក្នុង រដ្ឋធម្មនុញ្ញ មាត្រា២ ដែលរំលឹកឡើងវិញ នូវកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ សង្កត់ធ្ងន់ទៅលើ «**មោឃភាព នៃសន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយ ក្នុងទសវត្សទី៨០ ជាមួយភាគីវៀតណាម ដែលត្រួតត្រាកម្ពុជា យ៉ាងខុសច្បាប់អន្តរជាតិ**»។ *រដ្ឋធម្មនុញ្ញ មាត្រា ២ «បូរណភាពទឹកដីរបស់ ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់ ក្នុងផែនទីខ្នាត ១/១០០.០០០ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះ ឆ្នាំ ១៩៦៣-១៩៦៩»*។

ការបោះបង់ខ្សែព្រំដែនពីសម័យបារាំង ហើយបង្កើតខ្សែបន្ទាត់ព្រំដែនថ្មី តាមការចង់បានរបស់វៀតណាម មានន័យថា រដ្ឋាភិបាល ហ៊ុន សែន មានទោសស្មើនឹងធ្វើជាតិប្រហារ ឬក្បត់ជាតិ ពីព្រោះខ្សែបន្ទាត់ព្រំដែនថ្មី វាច្បាស់ជារំកិលព្រំដែន ទៅតាមខ្លឹមសារសន្ធិសញ្ញា ឬអនុសញ្ញាព្រំដែនថ្មីដែរ។ ដូច្នេះហើយ គេចាំបាច់ត្រូវតែ រកវិធីផលិតផែនទីថ្មី ដែលឆ្លុះបញ្ចាំង អំពីខ្សែបន្ទាត់ព្រំដែនថ្មី និង ទិដ្ឋភាពដីជាស្តែង។

**ប្រវត្តិសង្ខេបនៃការបោះបង្គោលព្រំដែន មាន ៣ ដំណាក់កាល៖**

**ក**. **ដំណាក់កាលទី១**៖ ***តាមអនុសញ្ញាបារាំង កម្ពុជា និង កូសាំស៊ីន(កម្ពុជាក្រោម) ឆ្នាំ ១៨៧៣ បានបោះបង្គោលព្រំដែន ចំនួន ១២៤ បង្គោល***។ បង្គោលទាំង ១២៤ បង្គោលនេះ ក្លាយជាព្រំដែនកម្ពុជា-វៀតណាម នៅពេលបារាំង កាត់ដីខ្មែរក្រោម ឲ្យវៀតណាម ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩។ ខ្សែបន្ទាត់ព្រំដែន និង ផែនទីព្រំដែននេះ ត្រូវបានទទួលស្គាល់ ដោយសន្និសីទអន្តរជាតិ ទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ស្តីពីកម្ពុជាទទួលឯករាជ្យពីបារាំង ហើយវៀតណាម និងឡាវ ក៏បានយល់ស្របដែរ។ ឯកសារព្រំដែន រវាងកម្ពុជា ជាមួយប្រទេសជិតខាង ត្រូវបានរំលឹកឡើងវិញ តាមកិច្ចព្រមព្រៀង ទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

**ខ**. **ដំណាក់កាលទី២**៖ សន្ធិសញ្ញាព្រំដែនខុសច្បាប់ ឆ្នាំ១៩៨៥ ដែលធ្វើឡើងក្នុងសម័យវៀតណាមត្រួតត្រាប្រទេសកម្ពុជា បានរំកិលខ្សែបន្ទាត់ព្រំដែន ចេញខ្សែរបន្ទាត់ព្រំដែនចាស់ ពីសម័យអាណានិគមបារាំង ចូលក្នុងបូរណភាពទឹកដីខ្មែរ ។ ***សន្ធិសញ្ញាថ្មីនេះ កម្ពុជា និងវៀតណាម បានបោះបង្គោលព្រំដែនថ្មី ចំនួន ៧២ បង្គោល នៅចន្លោះឆ្នាំ១៩៨៦-១៩៨៨*** ។ **ឯកសារសន្ធិសញ្ញាព្រំដែន និងការបោះបង្គោលព្រំដែន ធ្វើឡើងដោយឯកតោភាគី ពីព្រោះវៀតណាម** គឺជាអ្នករៀបចំសំណុំឯកសារ និង ផែនទីព្រំដែនរួចជាស្រេច ដើម្បីឲ្យរដ្ឋាភិបាលទីក្រុងភ្នំពេញរបស់លោក ហ៊ុន សែន ចុះហត្ថលេខា និងទទួលយល់ព្រម។

**គ**. **ដំណាក់កាលទី៣**៖ សន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ២០០៥ បានទទួលស្គាល់ឡើងវិញ នូវសន្ធិសញ្ញាព្រំដែនខុសច្បាប់ ឆ្នាំ១៩៨៥ ជាមួយវៀតណាម ដោយមានការរំកិលខ្សែបន្ទាត់ព្រំដែន ជាថ្មីម្តងទៀត ចូលមកក្នុងបូរណភាពទឹកដីខ្មែរ។ សន្ធិសញ្ញាថ្មីនេះ ***គ្រោងបោះព្រំដែនចំនួន ៣៥៣ បង្គោល និងអាចបោះបន្ថែម តាមការចាំបាច់*** ។ បច្ចុប្បន្ន ***រដ្ឋាភិបាល ហ៊ុន សែន និងរដ្ឋាភិបាលវៀតណាម បោះបង្គោលព្រំដែនបានជាង ៨៣% ហើយ*** ប្រើផែនទីអមសន្ធិសញ្ញាខុសច្បាប់ ឆ្នាំ១៩៨៥ និងប្រើផែនទី UTM ១/៥០.០០០។ **លោក វ៉ា គឹមហុង**



អសយដ្ឋានទំនាក់ទំនង ទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស៍ /ប្រអប់សំបុត្រ៖ # Senterveien 40, Apartment 112, 4790 Lillesand, NORWAY /Phone: (+47) 90 81 82 57 /E-mail: nathamonin@gmail.com

ទេសដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន របស់រដ្ឋាភិបាល បានសារភាពរឿងនេះ កាលពីថ្ងៃទី០២ និងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ថា«*ជាផែនទី ផលិតនៅប្រទេសវៀតណាម ។ ហើយវៀតណាម បង្ខំឲ្យភាគីកម្ពុជា ប្រើប្រាស់ផែនទី UTM ខ្នាត ១/៥០.០០០ ក្នុងការបោះបង្គោលព្រំដែន*» ។

## ៣. ភាពជម្រោងចម្រាស និង ផលវិបាក នៃសន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ២០០៥

សន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ២០០៥ ទៅលើសន្ធិសញ្ញាព្រំដែនរដ្ឋខុសច្បាប់ ឆ្នាំ១៩៨៥ ត្រូវបានប្រឆាំងជំទាស់យ៉ាងដាច់អហង្កា ពីក្រុមអ្នកជំនាញការព្រំដែនខ្មែរ នៅក្រៅប្រទេស, ពីក្រុមសកម្មជនព្រំដែន, អ្នកជំនាញការច្បាប់ និង ក្រុមសមាជិករដ្ឋសភា ពីគណបក្សប្រឆាំងសម-រង្ស៊ី។ **ខ្លឹមសារសន្ធិសញ្ញាព្រំដែនថ្មីនេះ បានរំលោភទាំងស្រុង ទៅលើរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា២ និង រំលោភទៅលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១** ស្ដីអំពីអធិបតេយ្យភាព និងភាពមិនអាចរំលោភបាននៃ បូរណភាពទឹកដីខ្មែរ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីស បានបញ្ជាក់ច្បាស់ថា «**កិច្ចព្រមព្រៀង ឬសន្ធិសញ្ញាទាំងឡាយណា ដែលធ្វើឡើងនៅទសវត្សទី ៨០ និងធ្វើឡើងដោយបង្ខំ ត្រូវបានដាក់ជាមោឃភាព**»។ ប៉ុន្តែលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បែរជាប្រឆាំងរដ្ឋធម្មនុញ្ញ និង កិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលជាឯកសារយ៉ាងសំខាន់របស់កម្ពុជាខ្លួនឯងទៅវិញ។

ករណីមានភាពជម្រោងចម្រាស និង ស្ថិតនៅក្រោមការគំរាមកំហែងនានា ដូចចំណុចខាងលើ រួមទាំងការគំរាមការផ្លាស់ប្ដូររបបដឹកនាំផង **នោះកម្ពុជា នៅតែមានសិទ្ធិប្ដឹងតវ៉ាទាមទារ យកផលប្រយោជន៍ និង បូរណភាពទឹកដីខ្មែររបស់ខ្លួនមកវិញ ពីប្រទេសវៀតណាម ដែលវៀតណាម បានបង្ខំឲ្យមេដឹកនាំខ្មែរជាសេនារីយ៉ូរបស់ខ្លួន អនុវត្តយុទ្ធសាស្ត្រនយោបាយរបស់ខ្លួន រំលោភលើច្បាប់របស់កម្ពុជា និង ច្បាប់អន្តរជាតិ។ ការប្ដឹងតវ៉ានេះ ត្រូវប្ដឹងទៅភាគីអន្តរជាតិពាក់ព័ន្ធនានា និង ត្រូវពឹងផ្អែកលើរដ្ឋាភិបាលថ្មីណាមួយ ដែលស្រឡាញ់ពលរដ្ឋ និង ជាតិ ទឹកដីខ្មែរ។**

**រំលឹក៖** សន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ថ្មីនេះ ត្រូវបានចុះហត្ថលេខាដោយលោក ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និងលោក ផាន វ៉ាន់ ខាយ នាយករដ្ឋមន្ត្រីវៀតណាម កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ ***ហើយព្រះមហាក្សត្រខ្មែរ នរោត្តម សីហមុនី បានឡាយព្រះហស្តលេខា លើព្រះរាជក្រមប្រកាសឲ្យប្រើប្រាស់ នៅថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០០៥ បន្ទាប់ពីរដ្ឋសភា និងព្រឹទ្ធសភា បានផ្ដល់សច្ចាប័នយល់ព្រម ក្រោមស្ថានភាពដ៏ជម្រោងចម្រាស ហើយនិងការគំរាមកំហែង*** **រួចមក។**

កំឡុងពេល សន្ធិសញ្ញាព្រំដែនបំពេញបន្ថែម កំពុងស្វែងរកការគាំទ្រពីស្ថាប័នកំពូលៗរបស់ជាតិ លោក ហ៊ុន សែន បានគំរាមផ្លាស់ប្ដូររបបដឹកនាំប្រទេស «**ពីរាជានិយម ទៅជាសាធារណរដ្ឋ**» បើសិនជា **ព្រះមហាក្សត្រមិនព្រមឡាយព្រះហស្តលេខាទេនោះ**។ កាលនោះព្រះមហាក្សត្រ នរោត្តម សីហមុនី បានយាងទៅទីក្រុងប៉េកាំង ប្រទេសចិន តាមការយាងពីព្រះមាតាបិតារបស់ព្រះអង្គ ដែលគង់នៅទីនោះ ប៉ុន្តែព្រះអង្គ ត្រូវប្រញាប់យាងត្រឡប់មកកម្ពុជាវិញជាបន្ទាន់ បន្ទាប់ពីលោក ហ៊ុន សែន បានគម្រាមផ្លាស់ប្ដូរបប។



អសយដ្ឋានទំនាក់ទំនង ទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស៍ /ប្រអប់សំបុត្រ៖ # Senterveien 40, Apartment 112, 4790 Lillesand, NORWAY /Phone: (+47) 90 81 82 57 /E-mail: nathamonin@gmail.com

ក្រុមមេដឹកនាំ នៃក្រុមប្រឹក្សឃ្លាំមើលកម្ពុជា ត្រូវបានលោក ហ៊ុន សែន ប្រកាសចាប់ខ្លួន នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥ ពោលគឺ ៣ ថ្ងៃក្រោយពីក្រុមប្រឹក្សានេះ បានចេញសេចក្តីថ្លែងការណ៍ ប្រឆាំងជំទាស់ សន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ដោយ«ប្រកាសកាន់មរណកាន់ទុក្ខ នៃការបាត់បង់បូរណភាពទឹកដីខ្មែរ»។ ពេលនោះ **លោក ម៉ែន ណាត** ប្រធានសមាគមមន្ត្រីរាជការកម្ពុជា, **លោក ឆាំ ឆានី** ប្រធានសមាគមឯករាជ្យកសិករកម្ពុជា, និង **លោក អៀ ចាន់ណា** អគ្គលេខាធិការរង នៃចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតយ្យ បានភៀសខ្លួនទៅប្រទេសថៃ រួចទទួលបានសិទ្ធិជ្រកកោនខាងនយោបាយ នៅប្រទេសន័រវេស៍ ហើយ **លោក ប៉ាង សុខឿន** ប្រធានចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ បានភៀសខ្លួនទៅថៃ រួចទទួលសិទ្ធិជ្រកកោន នៅប្រទេសស៊ុយអែត។ **លោក រ៉ុង ឈុន** ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ត្រូវបានចាប់ដាក់គុក ជាង ៣ ខែ ពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៥ ដល់ចុងខែមករា ឆ្នាំ២០០៦ ទើបត្រូវបានដោះលែង។ **លោក ជា មុន្នី** ប្រធានសហជីពសេរីកម្មករកម្ពុជា បានភៀសខ្លួន នៅប្រទេសបារាំង ៤ ខែ ពីខែតុលា ឆ្នាំ២០០៥ ហើយវិលចូលស្រុកវិញ នៅដើមខែកុម្ភៈ ឆ្នាំ២០០៦។

ដោយសារភាពជម្រោងចម្រាស ជំទាស់សន្ធិសញ្ញាព្រំដែនបំពេញបន្ថែមនេះដែរ **លោក ម៉ម សូណងដូ** នាយកវិទ្យុសំបុកឃ្មុំ ត្រូវបានចាប់ដាក់គុកជាង ៣ ខែ, **លោក ប៉ា ងួនទៀង** នាយកព័ត៌មាននៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានចាប់ខ្លួនដាក់ពន្ធនាគារជាង ១ ខែ, **លោក កឹម សុខា** កាលនោះជាប្រធាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ហើយនិង **លោក យេង វីរៈ** នាយកមជ្ឈមណ្ឌអប់រំច្បាប់សម្រាប់សហគមន៍ ក៏ត្រូវបានចាប់ខ្លួនដាក់គុកជាង ១ ខែដែរ ពីខែធ្នូ ឆ្នាំ២០០៥ ដល់ចុងខែមករា ឆ្នាំ២០០៦ ទើបត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញ ដំណាលគ្នាជាមួយ **លោក រ៉ុង ឈុន** ដែរ បន្ទាប់ពីមានសម្ពាធធ្ងន់ធ្ងរ ពីសហគមគមន៍អន្តរជាតិផង។

ជុំវិញភាពជម្រោងចម្រាស ប្រឆាំងជំទាស់ សន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ២០០៥ ដែលមានភាពមិនប្រក្រតីនោះ **លោក ស៊ាន ប៉េងសែ** ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា ប្រទេសបារាំង, **ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ** ទីប្រឹក្សាផ្ទាល់របស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ, និង **លោកបណ្ឌិតច្បាប់ សាយ បូរី** ក៏ទទួលបានការគំរាមកំហែងធ្ងន់ ពីលោក ហ៊ុន សែន ហើយមានការភៀសខ្លួនមួយរយៈ នៅចុងខែតុលា ឆ្នាំ២០០៥ និង ដើមឆ្នាំ២០០៦។

## ៤. ការឃាំឃឺននយោបាយ ពាក់ព័ន្ធការរឿងព្រំដែន និង ការរំលោភសិទ្ធិមនុស្ស

**សមាជិកព្រឹទ្ធសភា លោក ហុង សុខហួរ** ពីគណបក្សប្រឆាំង ត្រូវបានចាប់ខ្លួនភ្លាមៗ ទាំងនៅមានអភ័យឯកសិទ្ធិ កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ ក្រោយពេលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសឲ្យចាប់ខ្លួនក្រោមបទចោទប្រកាន់ថា «ផ្សាយឯកសារព្រំដែនក្លែងក្លាយ» ចំពេលបញ្ហាព្រំដែនឡើងកំដៅ ហើយតុលាការ បានកាត់ទោសរូបលោក យ៉ាងអយុត្តិធម៌ ឲ្យជាប់គុក ៧ ឆ្នាំ។ កាឃុំខ្លួនលោក ហុង សុខហួរ គឺជារឿងនយោបាយ និងជាការរំលោភ រដ្ឋធម្មនុញ្ញ មាត្រា១០៤ ថ្មី។



អសយដ្ឋានទំនាក់ទំនង ទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស៍ /ប្រអប់សំបុត្រៈ # Senterveien 40, Apartment 112, 4790 Lillesand, NORWAY /Phone: (+47) 90 81 82 57 /E-mail: nathamonin@gmail.com

**សមាជិសភា លោក អ៊ុំ សំអាន** ពីគណបក្សសង្គ្រោះជាតិ ជាសមាជិកសភាសកម្ម ក្នុងរឿងស្រាវជ្រាវផែនទីព្រំដែន និងដឹកនាំក្រុមការងារចុះពិនិត្យព្រំដែនខ្មែរ-វៀតណាម ត្រូវបានចាប់ខ្លួនដាក់គុក កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ពីបទចោទប្រកាន់ «ញុះញង់ឲ្យការប្រព្រឹត្តបទឧក្រិដ្ឋ រឿងព្រំដែន និង ជំរុញឲ្យរើសអើង» ហើយតុលាការ កាត់ទោសឲ្យជាប់ពន្ធនាគារ ២ ឆ្នាំ ៦ ខែ និងត្រូវបង់ពិន័យ ៤ លានរៀល។ លោក អ៊ុំ សំអាន គឺសមាជិកសភា ដែលស្រឡាញ់ជាតិ និងទឹកដី ហើយបានទៅស្រាវជ្រាវផែនទីព្រំដែន ពីអង្គការសហប្រជាជាតិ, បណ្ណាល័យសភាសហរដ្ឋអាមេរិក និង ពីវិទ្យាស្ថានជាតិភូមិសាស្ត្ររបស់បារាំង នៅទីក្រុងប៉ារីស ព្រមទាំងដឹកនាំក្រុមតំណាងរាស្ត្រ និងក្រុមយុវជន ទៅពិនិត្យព្រំដែនយ៉ាងផុលផុស។

ការចាប់ឃុំខ្លួន និងការកាត់ទោសសមាជិកសភា **លោក អ៊ុំ សំអាន** ប្រព្រឹត្តទៅទាំងងនៅមានអភ័យឯកសិទ្ធិជាតំណាងរាស្ត្រ។ ការចាប់ឃុំខ្លួននេះ គឺការរំលោភរដ្ឋធម្មនុញ្ញ មាត្រា ៨០ និង ជាការធ្វើឡើងតាមការចង់បានរបស់លោក ហ៊ុន សែន ដើម្បីបំបិទសេរីភាពបញ្ចេញមតិ និងបង្ក្រាបក្រុមសកម្មជនព្រំដែនឯទៀត ដែលឈឺឆ្អាលរឿងព្រំដែន ដ៏ជម្រោងចម្រាស។

ដោយឡែក ក្រុមសកម្មជនដែលសកម្មក្នុងរឿងព្រំដែន និង ក្រុមមន្ត្រីសិទ្ធិមនុស្សជាង ២០ នាក់ កំពុងជាប់ឃុំឃាំងយ៉ាងអយុត្តិធម៌ ក្រោមសម្ពាធនៃចំណាត់ការនយោបាយ ដែលគ្មានគុណធម៌, រំលោភសិទ្ធិមនុស្ស និងរំលោភច្បាប់ធ្ងន់ធ្ងរ ពីសំណាក់រដ្ឋាភិបាល ហ៊ុន សែន។ ជាមួយគ្នានេះ **លោក សម រង្ស៊ី** មេដឹកនាំគណបក្សសង្គ្រោះជាតិ ក៏កំពុងនីរទេសខ្លួន នៅប្រទេសបារាំង គេចចេញពីការចាប់ឃុំខ្លួន ពីរដ្ឋាភិបាល ហើយលោក **កឹម សុខា** មេដឹកនាំទី២ នៃគណបក្សនេះ ក៏ត្រូវបានជាប់ឃុំខ្លួនឯង ក្នុងទីស្នាក់ការគណបក្ស ក្រោយពីតុលាការ ក្រោមការបង្គប់បញ្ជារបស់លោក ហ៊ុន សែន តាមយាយីខាងនយោបាយ។ អ្នកវិភាគសង្គម **លោកបណ្ឌិត កែម ឡី** ត្រូវបានបាញ់សម្លាប់យ៉ាងឃោរឃៅ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ ដែលពាក់ព័ន្ធការវិភាគរបស់លោក តាមវិទ្យុ និងបណ្តាញសារព័ត៌មាននានា ទៅលើរបាយការណ៍ របស់អង្គការបរិស្ថានពិភពលោក Global Witness ស្តីពីត្រកូល ហ៊ុន របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន រកស៊ីខុសច្បាប់ និង រំលោភសិទ្ធមនុស្ស។ បេសកម្មលោក កែម ឡី មួយទៀត គឺយុទ្ធនាការ ១០០ រាត្រី ដែលធ្វើការស្រាវជ្រាវរឿងព្រំដែនខ្មែរ-យួន, រឿងអន្តោប្រវេសន៍ខុសច្បាប់, និងរឿងក្រុមហ៊ុនរកស៊ីខុសច្បាប់ របស់ពួកមន្ត្រីរដ្ឋាភិបាល។ ឃាតកម្មនេះ មិនទាន់ត្រូវបានរែកមុខឃាតកទេ ហើយក៏ត្រូវបានដាក់ការសង្ស័យ ទៅលើមនុស្សក្នុងត្រកូល ហ៊ុន ជាមេគំនិតផងដែរ។

ភាពជម្រោងចម្រាសរឿងព្រំដែនកម្ពុជា-វៀតណាម ដោយសាររដ្ឋាភិបាល ហ៊ុន សែន ប្រើប្រាសផែនទីមិនទាន់ត្រឹមត្រូវ, ខ្វះការចូលរួមពីអ្នកជំនាញការឯករាជ្យ, ផ្ទៀងផ្ទាត់ផែនទី ដោយមិនផ្ទៀងលើដីជាក់ស្តែង, បង្គោលព្រំដែនថ្មី មិននៅលើទីតាំងបង្គោលចាស់ ពីសម័យបារាំង, ពលរដ្ឋតាមព្រំដែន បាត់បង់ដីស្រែចំការ, និងការចាប់សកម្មជន ដាក់គុក។ ម៉្លោះហើយទើបពលរដ្ឋខ្មែរ បាត់បង់ទំនុកចិត្ត លើរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាព្រំដែន ជាមួយវៀតណាម។ ការប្រើផែនទីខុស នៅក្នុងការបោះបង្គោលព្រំដែនបច្ចុប្បន្ន គឺជាហេតុធ្វើឲ្យមានការគំរាមកំហែងពី រដ្ឋាភិបាល បោះជហានទៅរកការធ្វើវិសោធនកម្ម រដ្ឋធម្មនុញ្ញ មាត្រា២។



អសយដ្ឋានទំនាក់ទំនង ទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស៍ /ប្រអប់សំបុត្រ៖ # Senterveien 40, Apartment 112, 4790 Lillesand, NORWAY /Phone: (+47) 90 81 82 57 /E-mail: nathamonin@gmail.com

## ៥. យន្តការដោះស្រាយបញ្ហាព្រំដែនខ្មែរ

៥.១. មិនត្រូវមានការផ្ទេរខ្នាតផែនទីអ្វីទាំងអស់ ក្នុងកាលៈទេសៈនយោបាយសព្វថ្ងៃ ខណៈពេលដែលរដ្ឋាភិបាល ហ៊ុន សែន បាននិងកំពុងប្រើប្រាសផែនទី UTM ខ្នាត ១/៥០.០០០ បោះបង្គោលព្រំដែន បានជាង ៨៣% មកដល់ពេលនេះ។

៥.២. ត្រូវរក្សាខ្លឹមសារដើមនៃ មាត្រា២ រដ្ឋធម្មនុញ្ញ ដោយមិនមានកែប្រែឡើយ ពីព្រោះវាមានសារសំខាន់ភ្ជាប់ខ្លឹមសារឯកសារជាប្រវត្តិសាស្ត្រ ដែលមានការទទួលស្គាល់ជាអន្តរជាតិរួចមកហើយ។

៥.៣. ត្រូវអនុម័តលុបចោលសន្ធិសញ្ញាទាំងអស់ ដែលផ្ទុយខ្លឹមសារកិច្ចព្រមព្រៀង ទីក្រុងប៉ារីស ឆ្នាំ ១៩៩១ ផ្ទុយមាត្រា២ រដ្ឋធម្មនុញ្ញ និង ត្រូវលុបចោល សន្ធិសញ្ញាព្រំដែនបំពេញបន្ថែម ឆ្នាំ២០០៥ ដោយរដ្ឋសភាជាតិ។

៥.៤. (រដ្ឋាភិបាល) ត្រូវប្តឹងរឿងនេះ ទៅសហប្រធានហត្ថលេខី នៃកិច្ចព្រមព្រៀង ក្រុងប៉ារីស ឆ្នាំ១៩៩១ ដោយភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធនានា។

៥.៥. ត្រូវលើកបញ្ហាព្រំដែននេះ ប្តឹងភាគីវៀតណាម ទៅតុលាការយុត្តិធម៌អន្តរជាតិ នៅទីក្រុងឡាអេ ដូចករណីប្រាសាទព្រះវិហារ នៅជាប់ព្រំដែនថៃ កាលីឆ្នាំ១៩៦២ ដែរ។

**ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ម៉ែន ណាត**



អសយដ្ឋានទំនាក់ទំនង ទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស៍ /ប្រអប់សំបុត្រ៖ # Senterveien 40, Apartment 112, 4790 Lillesand, NORWAY /Phone: (+47) 90 81 82 57 /E-mail: nathamonin@gmail.com